# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ ៨៨៨៣.១.... សហវ......

ថ្ងៃ សុក្រ ៣ រោច ខែ ស្រាពណ៍ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០២០

**ជម្រាបជូន**

**-លោក លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត**

**-លោក លោកស្រីប្រធានសាខាពន្ធដាររាជធានី-ខេត្ត**

**-លោក លោកស្រីប្រធានសាខាគយនិងរដ្ឋាករាជធានី-ខេត្ត**

**-លោក លោកស្រីប្រធានរតនាគាររាជធានី-ខេត្ត**

**កម្មវត្ថុ ÷** ការចុះត្រួតពិនិត្យ ថែទាំ និង ជួសជុលឧបករណ៍សម្ភាររបស់គម្រោង FMIS សម្រាប់ត្រីមាសទី៣ ឆ្នាំ ២០២០ ព្រមទាំងដាក់ឱ្យដំណើរការប្រព័ន្ធបណ្តាញខ្សែកាប្លិ៍អុបទិច (BACKUP LINK) និង សិក្សាប្លង់ទីតាំងដែលត្រូវដាក់ដំឡើងប្រព័ន្ធ Video Conference ។

**ភ្ជាប់ជូន ÷** តារាងកាលវិភាគ និង សមាសភាពមន្ត្រីចុះបេសកកម្ម ។

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប **លោក លោកស្រីប្រធាន** ជ្រាបថា ស្របតាមផែនការសកម្មភាពដែលបានគ្រោងទុក ក្រុមការងារគ្រប់គ្រងគម្រោង FMIS របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចុះត្រួតពិនិត្យ ថែទាំ និង ជួសជុលឧបករណ៍សម្ភារបច្ចេកវិទ្យាព័ត៌មាន និង មិនមែនបច្ចេកវិទ្យាព័ត៌មានរបស់គម្រោង FMIS រួមមាន÷ ម៉ាស៊ីនកុំព្យូទ័រ, ម៉ាស៊ីនស្កេន, ម៉ាស៊ីនព្រីន, ឧបករណ៍បណ្តាញតភ្ជាប់ និង ឧបករណ៍សម្ភារមួយចំនួនទៀត នៅគ្រប់ការដ្ឋានរបស់គម្រោង FMIS សម្រាប់ត្រីមាសទី៣ ឆ្នាំ ២០២០ ដើម្បីធានាថាឧបករណ៍សម្ភារទាំងអស់ដំណើរការបានល្អ និង ប្រើប្រាស់បានយូរអង្វែង សម្រាប់ទ្រទ្រង់ដល់ការប្រើប្រាស់ប្រព័ន្ធ FMIS ឱ្យប្រព្រឹត្តទៅដោយរលូន និង តាមតម្រូវការ ។ ស្របពេលជាមួយគ្នានេះ ក្រុមការងារក៏នឹងត្រូវដាក់ឱ្យដំណើរការប្រព័ន្ធបណ្តាញខ្សែកាប្លិ៍អុបទិច (BACKUP LINK) នៅតាមការដ្ឋាននីមួយៗរបស់គម្រោងអ៊ីនត្រាណិត និង ចុះសិក្សាប្លង់ទីតាំងដែលត្រូវដាក់ដំឡើងប្រព័ន្ធ Video Conference នៅតាមរតនាគាររាជធានី-ខេត្ត, សាខាគយនិងរដ្ឋាកររាជធានី-ខេត្ត និង សាខាពន្ធដាររាជធានី-ខេត្ត ដូចមានក្នុងតារាងកាលវិភាគដែលបានជូនភ្ជាប់ ។

អាស្រ័យហេតុនេះ សូម **លោក លោកស្រីប្រធាន** ជួយសម្របសម្រួលដល់ការចុះបំពេញភារកិច្ចខាងលើឱ្យសម្រេចបានជោគជ័យតាមផែនការដែលបានគ្រោងទុក តាមការគួរ ។ សម្រាប់ព័ត៌មានបន្ថែម ឬ ចម្ងល់ផ្សេងៗ សូមទំនាក់ទំនងមកលោក **ឡាញ់ គីមវ៉ុន** តាមរយៈទូរស័ព្ទលេខ **០១៧ ៨៥ ០៥ ៥១** ឬ **០៦៩ ៨៦ ៨៧ ៦៥** ។

សូម **លោក លោកស្រីប្រធាន** ទទួលនូវការរាប់អានពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**រដ្ឋលេខាធិការ**

បណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**

***ចម្លងជូន ÷***

- *ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ*
- *អគ្គលេខាធិការដ្ឋាន កសហវ*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានរតនាគារជាតិ*

  *"ដើម្បីគោរពជូនជ្រាប"*
- *ឯកសារ-កាលប្បវត្តិ*

ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ:(+៨៥៥)២៣៨៤០៦៦៦

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ..៧៨៨៤..សហវ.......

ថ្ងៃ [illegible] ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០២០

**ជម្រាបជូន**

- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងបរិស្ថាន**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងព័ត៌មាន**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសុខាភិបាល**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា**
- **លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ**
- **ឯកឧត្តមរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

**កម្មវត្ថុ** ÷ ការចុះត្រួតពិនិត្យ ថែទាំ និង ជួសជុលឧបករណ៍សម្ភាររបស់គម្រោងFMIS សម្រាប់ត្រីមាសទី៣ ឆ្នាំ ២០២០ ព្រមទាំងដាក់ឱ្យដំណើរការប្រព័ន្ធបណ្តាញខ្សែកាប្លិ៍អុបទិច (BACKUP LINK) ។

**ភ្ជាប់ជូន** ÷ តារាងកាលវិភាគ និង សមាសភាពមន្ត្រីចុះបេសកកម្ម ។

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី** ជ្រាបថា ស្របតាមផែនការសកម្មភាពដែលបានគ្រោងទុក ក្រុមការងារគ្រប់គ្រងគម្រោង FMIS របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចុះត្រួតពិនិត្យ ថែទាំ និង ជួសជុលឧបករណ៍សម្ភារបច្ចេកវិទ្យាព័ត៌មាន និង មិនមែនបច្ចេកវិទ្យាព័ត៌មានរបស់គម្រោង FMIS រួមមាន÷ ម៉ាស៊ីនកុំព្យូទ័រ, ម៉ាស៊ីនស្កេន, ម៉ាស៊ីនព្រីន, ឧបករណ៍បណ្តាញតភ្ជាប់ និង ឧបករណ៍សម្ភារមួយចំនួនទៀត នៅគ្រប់ការដ្ឋានរបស់គម្រោង FMIS សម្រាប់ត្រីមាសទី៣ ឆ្នាំ ២០២០ ដើម្បីធានាថាឧបករណ៍សម្ភារទាំងអស់ដំណើរការបានល្អ និង ប្រើប្រាស់បានយូរអង្វែង សម្រាប់ទ្រទ្រង់ដល់ការប្រើប្រាស់ប្រព័ន្ធ FMIS ឱ្យប្រព្រឹត្តទៅដោយរលូន និង តាមតម្រូវការ ។ ស្របពេលជាមួយគ្នានេះ ក្រុមការងារក៏នឹងត្រូវដាក់ឱ្យដំណើរការប្រព័ន្ធបណ្តាញខ្សែកាប្លិ៍អុបទិច (BACKUP LINK) នៅតាមការដ្ឋាននីមួយៗរបស់គម្រោងអ៊ីនត្រាណិត ដូចមានក្នុងតារាងកាលវិភាគដែលបានជូនភ្ជាប់ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី** ជួយសម្របសម្រួលដល់ក្រុមការងារគ្រប់គ្រងគម្រោង FMIS ក្នុងការចុះបំពេញភារកិច្ចខាងលើប្រកបដោយជោគជ័យតាមផែនការដែលបានគ្រោងទុក តាមការគួរ ។ សម្រាប់ព័ត៌មានបន្ថែម ឬ ចម្ងល់ផ្សេងៗ សូមទំនាក់ទំនងមកលោក **ឡាញ់ គីមវ៉ុន** តាមរយៈទូរស័ព្ទលេខ **០១៧ ៨៥ ០៥ ៥១** ឬ **០៦៩ ៨៦ ៨៧ ៦៥** ។

សូម **ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី** ទទួលការរាប់អានពីខ្ញុំ៕

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋលេខាធិការ**

**បណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប**

***<u>ចម្លងជូន ៖</u>***

- *ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ*
  *"ដើម្បីគោរពជូនជ្រាប"*
- *ឯកសារ-កាលប្បវត្តិ*